ក

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 11 ខែ 06 ឆ្នាំ 2003

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១០-៩-២០០១ | - ព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០១/៣២៤ស្តីពីការបំពាក់មេដាយការពារជាតិ ជូននាយទាហានជាន់ខ្ពស់ក្នុងក្របខ័ណ្ឌចំនួន ០៩ រូប ក្នុង ០១រូប១ចំនួន ០៦គ្រឿង | ២៥២៨ |
| ១០-៩-២០០១ | - ព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០១/៣២៥ ស្តីពីការបំពាក់មេដាយសេនាជ័យសិទ្ធ ជូននាយទាហានជាន់ខ្ពស់ក្នុងក្របខ័ណ្ឌចំនួន ២៨ រូប | ២៥៣០ |
| ១០-៩-២០០១ | - ព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០១/៣២៦ ស្តីពីការបំពាក់មេដាយសេនាជ័យសិទ្ធ ជូននាយទាហានជើងចាស់ចំនួន ១០រូប | ២៥៣២ |
| ១១-៩-២០០១ | - ព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០១/៣២៧ស្តីពីការតែងតាំងសមាសភាព នៃក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិនៅអមខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា | ២៥៣៤ |
| ១៤-៩-២០០១ | - ព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០១/៣៣១ ស្តីពីការតែងតាំងឯកឧត្តម **តាន់ ស៊ីថាន់** ជាទីប្រឹក្សាប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា | ២៥៣៦ |
| ២២-៩-២០០១ | - ព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០១/៣៣៤ ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី នាយទាហានជាន់ខ្ពស់នៃកងយោធពលមេរភូមិន្ទ | ២៥៣៧ |


## I- រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


| | | |
|---|---|---|
| ១០-៩-២០០១ | -អនុក្រឹត្យលេខ ៩១ អនក្រ បក. ស្តីពីការផ្ទេរឥណទានថវិកា | ២៥៣៨ |
| ១២-៩-២០០១ | អនុក្រឹត្យលេខ៩២អនក្រ.បក.ស្តីពីនីតិវិធីនៃការបើកផ្តល់មុនដោយអាណត្តិបើកប្រាក់សំរាប់<br>* ចំណាយដំណើការរៀបចំការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត<br>* ចំណាយមូលនិធិសំរាប់ជួសជុលថែទាំផ្លូវថ្នល់<br>* ចំណាយសំរាប់កម្មវិធីអភិវឌ្ឍន៍សុខាភិបាលស្រុកប្រតិបត្តិឈានមុខ(ADD)និងចំណាយសំរាប់កម្មវិធីសកម្មភាពជាអាទិភាព(PAP) | ២៥៤០ |
| ១៤-៩-២០០១ | -អនុក្រឹត្យលេខ ៩៣ អនក្រ បក. ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលនិងសុក្រឹតការវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា | ២៥៤៣ |
| ២០-៩-២០០១ | -អនុក្រឹត្យលេខ ៩៤ អនក្រ.បកស្តីពីការបង្កើតការរៀបចំនិងការប្រព្រឹត្តិទៅនៃលេខាធិការដ្ឋានឋបនីយជីវមណ្ឌលបឹងទន្លេសាប | ២៥៤៥ |
| ២១-៩-២០០១ | -អនុក្រឹត្យលេខ ៩៥ អនក្រ បក. ស្តីពីការផ្ទេរឥណទានថវិកា | ២៥៤៩ |

១០-៩-២០០១ -អនុក្រឹត្យលេខ ៤០៩ អនក្រ តត. ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៥៥១

១១-៩-២០០១ -អនុក្រឹត្យលេខ ៤១០ អនក្រ តត. ស្ដីពីការជូនមេដាយការងារ ២៥៥២

១១-៩-២០០១ -អនុក្រឹត្យលេខ ៤១១ អនក្រ តត. ស្ដីពីការជូនមេដាយសហមេត្រី ២៥៥៤

១២-៩-២០០១ -អនុក្រឹត្យលេខ ៤១២ អនក្រ តត. ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៥៥៥

១២-៩-២០០១ -អនុក្រឹត្យលេខ ៤១៣អនក្រ តត. ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៥៥៦

១២-៩-២០០១ -អនុក្រឹត្យលេខ ៤១៤ អនក្រ តត. ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៥៥៧

១២-៩-២០០១ -អនុក្រឹត្យលេខ ៤១៥អនក្រ តត. ស្ដីពីការតែងតាំងផ្ទេរភារកិច្ចមន្ត្រីរាជការ ២៥៥៨

១៣-៩-២០០១ -អនុក្រឹត្យលេខ ៤១៦ អនក្រ តត. ស្ដីពីការជូនមេដាយសុវត្ថារា ២៥៦០


## ២~ សេចក្ដីសំរេច


២០-៩-២០០១ សេចក្ដីសំរេចលេខ ៩៧ សសរ ស្ដីពីការបន្ថែមសមាសភាពគណៈកម្មការចំរុះអន្តរក្រសួងដោះស្រាយបញ្ហារថយន្តចង្កូតស្ដាំ ២៥៦១


## ៣~ សារាចរ


១៣-៩-២០០១ - សារាចរលេខ ០៦ សរ ស្ដីពីការរៀបចំការងារតំកល់ឯកសារជាតិ ២៥៦៣


## II- ការងារបណ្ដាក្រសួង

### ១~ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា


១០-៩-២០០១ - ប្រកាសលេខ ២៧៨២/០១ កអក/គជនា ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៥៦៨


### ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ


១០-៩-២០០១ - ប្រកាសលេខ ១២៨ ប្រក.កអជ ស្ដីពីការចាត់តាំងក្រុមការងារនិងក្រុមជំនាញសំរាប់គំរោងការអភិវឌ្ឍន៍កសិកម្មក្រោមធនាគារអភិវឌ្ឍន៍អាស៊ី លេខ 1445-CAM(SF) ២៥៧០


### ៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា~ព្រឹទ្ធសភានិងអធិការកិច្ច


២០-៩-២០០១ - សេចក្ដីសំរេចលេខ ០០៥/០១ ទរពអ .សសរ ស្ដីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិមន្ត្រីរាជការដែលត្រូវជូនគ្រឿងឥស្សរិយយស ២៥៧២


### ៤~ ទីស្ដីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិ សម្បទា


២០-៩-២០០១ - ប្រកាសលេខ ២៣០ ស.ក.ប.យ. ស្ដីពីការបង្កើតគណៈកម្មការកសាង លក្ខន្តិកៈ ដោយឡែករបស់ក្រសួងសង្គមកិច្ចការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ២៥៧៤

២០-៩-២០០១ - ប្រកាសលេខ ២៣១ ស.ក.ប.យ. ស្ដីពីការបង្កើតក្រុមការងារពិនិត្យនិងការពារ សេចក្ដីព្រាងច្បាប់ស្ដីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ២៩៧៦

២០-៩-២០០១ **៥. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

- សេចក្ដីសំរេចលេខ ០៩.៨៧៩/០១ គជប ស្ដីពីការតែងតាំងអនុគណៈកម្មាធិការអចិន្ត្រៃយ៍ ផ្នែកសន្តិសុខនៃ គ.ជ.ប ២៩៧៨

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣២៨

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សំណើរបស់ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានបំពាក់មេដាយការពារជាតិ ជូននាយទាហានជាន់ខ្ពស់ក្នុងក្របខ័ណ្ឌចំនួន០៩រូប ក្នុងមួយរូបៗចំនួន០៦គ្រឿង គឺមាស០២គ្រឿង ប្រាក់០២គ្រឿង និងសំរឹទ្ធ០២គ្រឿង ដូចមានរាយនាមខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១-ឧត្តមសេនីយ៍ឯក | ដៅ | ដំ | អត្តលេខ ០០០០៦៣ | នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន |
| ២- ឧត្តមនាវីទោ | មាស | ថន | អត្តលេខ ០០០០៩៤ | មេបញ្ជាការរង កងទ័ពជើងទឹក |
| ៣- ឧត្តមសេនីយ៍ត្រី | ចៅ | សែនជំនោរ | អត្តលេខ ០០០១៩៨ | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៤- ឧត្តមសេនីយ៍ត្រី | សាំង | គង់ | អត្តលេខ ០០៤៣២៥ | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៥- ឧត្តមសេនីយ៍ត្រី | សូ | ហុង | អត្តលេខ ០០៤៣២៣ | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៦- ឧត្តមសេនីយ៍ត្រី | ឌុល | សារឿន | អត្តលេខ ០០៤៣២៤ | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៧- ឧត្តមសេនីយ៍ត្រី | ញ៉ុំ | ស៊្វ | អត្តលេខ ០០៣៨០៨ | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៨- ឧត្តមសេនីយ៍ត្រី | ចំរើន | ជាតិ | អត្តលេខ ០០០១១០ | ទីប្រឹក្សា ក្រសួងការពារជាតិ |

៩៩-

៩- លោក ដួង ឆេង ទីប្រឹក្សា ព្រះអង្គម្ចាស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

មាត្រា២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។ល។

ព្រះហស្តលេខា

នរោត្តម សីហនុ

រាជធានីភ្នំពេញថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០០១

លេខ: ២២៧ចំ.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣២៥

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សំណើរបស់ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានបំពាក់មេដាយ ឈនជ័យសិទ្ធ ជូននាយទាហានជាន់ខ្ពស់ក្នុងក្របខ័ណ្ឌចំនួន២៨រូប ដូចមានរាយនាមខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១-ឧត្តមសេនីយ៍ឯក | ផាន់ | ខួន | អត្តលេខ ០០០០៤៩ | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ |
| ២-ឧត្តមសេនីយ៍ឯក | នី | ឃីម៉ុន | អត្តលេខ ០០០០៨៣ | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ |
| ៣-ឧត្តមសេនីយ៍ឯក | ស៊ុំ | ស៊ុនគិច | អត្តលេខ ០០០០៥៦ | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៤-ឧត្តមសេនីយ៍ឯក | ម៉ុច | សំផន | អត្តលេខ ០០០០៧១ | អគ្គនាយក អគ្គនាយកដ្ឋានភ័ស្តុភារហិរញ្ញវត្ថុ |
| ៥-ឧត្តមសេនីយ៍ឯក | ឈាង | ផាត | អត្តលេខ ០០០០៨០ | អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា |
| ៦-ឧត្តមសេនីយ៍ឯក | ចៅ | គិរុណ | អត្តលេខ ០០០០៧៥ | អគ្គនាយកអគ្គនាយកដ្ឋានសំភារៈបច្ចេកទេស |
| ៧-ឧត្តមសេនីយ៍ឯក | ជុំ | ឈាង | អត្តលេខ ០០០០២៤ | នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន |
| ៨-ឧត្តមសេនីយ៍ឯក | ម៉ស់ | ភ្នីប | អត្តលេខ ០០០០៤៣ | នាយរងសេនាធិការចំរុះ និងជានាយកនាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋាន |
| ៩-ឧត្តមសេនីយ៍ឯក | ញឹក | ហួន | អត្តលេខ ០០០០៩០ | នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន |
| ១០-ឧត្តមសេនីយ៍ឯក | អ៊ួង | ស៊ីផាន | អត្តលេខ ០០០០៩១ | នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន |
| ១១-ឧត្តមសេនីយ៍ឯក | ជា | តាក | អត្តលេខ ០០០១៨៣ | នាយរងសេនាធិការចំរុះ និងជានាយកទីចាត់ការភស្តុភារ អគ្គបញ្ជាការដ្ឋាន ...|

| | | | | |
|---|---|---|---|---|
| ១២-ឧត្តមសេនីយ៍ឯក | ហ៊ុន | តឿង | អត្តលេខ ០០០១៨៥ | នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន |
| ១៣-ឧត្តមសេនីយ៍ឯក | ឈុំ | សុជាតិ | អត្តលេខ ០០០០៣០ | នាយរងសេនាធិការចំរុះ និងជានាយកទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន |
| ១៤ ឧត្តមសេនីយ៍ឯក | ហោ | ប៊ុនិន្ន | អត្តលេខ ០០០១៥៧ | នាយសេនាធិការកងអគ្គភាគបន្ទន់និងនាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន |
| ១៥-ឧត្តមសេនីយ៍ឯក | នៅ | សំ | អត្តលេខ ០០០០៦៣ | នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន |
| ១៦-ឧត្តមសេនីយ៍ឯក | ទូរ | ឈាន | អត្តលេខ ០០០១៤៣ | មេបញ្ជាការរង កងទ័ពជើងគោក |
| ១៧-ឧត្តមសេនីយ៍ឯក | សិទ្ធ | ធី | អត្តលេខ ០០០០៣៩ | មេបញ្ជាការរង កងទ័ពជើងគោក |
| ១៨ ឧត្តមសេនីយ៍ឯក | ជា | សារ៉ន | អត្តលេខ ០០០០៩០ | មេបញ្ជាការរង និងជានាយសេនាធិការកងទ័ពជើងគោក |
| ១៩-ឧត្តមសេនីយ៍ឯក | ននៅ | សុខា | អត្តលេខ ០០០១០៥ | មេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស |
| ២០-ឧត្តមសេនីយ៍ឯក | សឹម | សំណាង | អត្តលេខ ០០០១០១ | មេបញ្ជាការ កងទ័ពជើងអាកាស |
| ២១-ឧត្តមនាវីឯក | អ៊ុំ | សំខាន់ | អត្តលេខ ០០០០៤៧ | មេបញ្ជាការ កងទ័ពជើងទឹក |
| ២២-ឧត្តមសេនីយ៍ឯក | ខ្វាន់ | សាម៉ | អត្តលេខ ០០០១០៨ | មេបញ្ជាការកងវិស្វកម្ម អគ្គបញ្ជាការដ្ឋាន |
| ២៣-ឧត្តមសេនីយ៍ទោ | ព្រហ្ម | ធិន | អត្តលេខ ០០០០៣៦ | មេបញ្ជាការ យោធភូមិភាគពិសេស |
| ២៤-ឧត្តមសេនីយ៍ទោ | ថាច | គង់ | អត្តលេខ ០០០១២០ | មេបញ្ជាការ យោធភូមិភាគទី១ |
| ២៥-ឧត្តមសេនីយ៍ទោ | ជៀន | សុខណ្ឌថា | អត្តលេខ ០០០០៣៨ | មេបញ្ជាការ យោធភូមិភាគទី២ |
| ២៦ ឧត្តមសេនីយ៍ទោ | តែច | សាម្ងួន | អត្តលេខ ០០០១២៩ | មេបញ្ជាការ យោធភូមិភាគទី៣ |
| ២៧-ឧត្តមសេនីយ៍ទោ | ជា | ម៉ិន | អត្តលេខ ០០០១៣៥ | មេបញ្ជាការ យោធភូមិភាគទី៤ |
| ២៨-ឧត្តមសេនីយ៍ទោ | ប៊ុន | សេង | អត្តលេខ ០០០១៤៥ | មេបញ្ជាការ យោធភូមិភាគទី៥ |

មាត្រា២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។ល។

ព្រះហស្ថលេខា

នរោត្តម សីហនុ

លេខ: ២២៨ ...

ដើម្បីចម្លង...

...ធានីភ្នំពេញថ្ងៃទី ... ឆ្នាំ២០០១

... ថ្ងៃទី ១៣ ... កញ្ញា ... ២០០១

អគ្គលេខាធិការ ...

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣២៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត គ្រឿងឥស្សរិយយសជាតិ
- បានទ្រង់យល់សំណើរបស់ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានបំពាក់មេដាយ សេនាជ័យសិទ្ធ ជូននាយទាហានជើងចាស់ចំនួន១០រូប ដូចមានរាយនាមខាងក្រោម ៖

១-ឧត្តមសេនីយ៍ឯក ណាធី តាន់ អត្តលេខ ០០០០៤៦ អគ្គលេខាធិការ រាជរដ្ឋាភិបាល

២-ឧត្តមសេនីយ៍ឯក ឆា ចំរ៉ើន អត្តលេខ ០០១០០៧ ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារការពារសន្តិសុខសណ្តាប់ធ្នាប់ សំរាប់ការបោះឆ្នោតជាទូទៅ

៣-ឧត្តមសេនីយ៍ឯក ញឹក ប៊ុនឆៃ អត្តលេខ ០០០០០៩ អនុប្រធានទី២ ព្រឹទ្ធសភា

៤-ឧត្តមសេនីយ៍ឯក ញឹម វណ្ណដា អត្តលេខ ០០០០១៩ សមាជិក សភាមណ្ឌលព្រៃវែង

៥-ឧត្តមសេនីយ៍ឯក ទឹម សារ៉ាន់ណូ អត្តលេខ ០០០០៣៣ អគ្គនាយកមជ្ឈមណ្ឌលកំចាត់មីន

៦-ឧត្តមសេនីយ៍ឯក អ៊ុំ ម៉ាណ្ឌីន អគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅសាធារណៈរដ្ឋប្រជាមានិត ប្រជាធិបតេយ្យកូរ៉េ

៧-ឧត្តមសេនីយ៍ឯក ប៊ូ ហ៊ិល ឧត្តមទីប្រឹក្សាផ្ទាល់ ព្រះមហាក្សត្រ

៨-ឧត្តមសេនីយ៍ឯក អ៊ុច ឌិន មន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ៩៩.

៩-ឧត្តមសេនីយ៍ឯក ថាច់ ផិន អត្តលេខ ០០០០៧៥ ទីប្រឹក្សាព្រះប្រធានរដ្ឋសភា

១០-ឧត្តមសេនីយ៍ឯក ឧង ចាយ អត្តលេខ ០០០០៧៣

**មាត្រា២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។ ល.ក.

ព្រះហស្តលេខា

នរោត្តម សីហនុ

រាជធានីភ្នំពេញថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០០១

លេខៈ ២២៥ ច.ល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស / រកត /០៩០១/៣២៧ យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

មាត្រា ១ : ត្រូវបានតែងតាំងសមាសភាពនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ នៅអមខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដូចមានរាយនាមខាងក្រោម ÷

១- ឯកឧត្តម សួស សូមេត ជាប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ ទេសរដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- ឯកឧត្តម អ៊ួន ព័ន្ធមុនីរ័ត្ន ជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

៣- ឯកឧត្តម សុន គន្ធរ ជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

៤- ឯកឧត្តម ហង់ជួន ណារ៉ុន ជាអគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

៥- ឯកឧត្តម សុខ ចិន្តា ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។/.

៦- ឯកឧត្តម ឈៀង យ៉ាណារ៉ា ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

៧- ឯកឧត្តម វង្ស៊ី វិស្សុត ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/០៩ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៩ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។ល។

ព្រះហស្តលេខា

នរោត្តម សីហនុ

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០១

លេខៈ ២២២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣៣១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ៦២៩ រស ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១
- យោងតាមសំណូមពរការងារចាំបាច់

**ត្រាស់បង្គាប់**

**មាត្រា ១ .-** តែងតាំងឯកឧត្តម **តាន់ ស៊ីថាន់** ជាទីប្រឹក្សាប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០១

លេខ: ៤៣៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ ១០ ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង ឡុន ? តាន់

សុខ តាន់

នស/រកត/០៩០១/៣៣៤

# ព្រះរាជក្រឹត្យ

## យើង

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្ដីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន
- បានទ្រង់យល់សំណើរបស់ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរសក្ដិ ថ្នាក់ឧត្តមសេនីយ៍ត្រី នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទដែលមានរាយនាមដូចខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១ វរសេនីយ៍ឯក | គឹម | គន្ធា | អត្តលេខ០០២៤៦៧ | នាយកដ្ឋានចំណាត់ការកលយុទ្ធអគ្គបញ្ជាការដ្ឋាន |
| ២-វរសេនីយ៍ឯក | ម៉ា | សារិទ្ធន | អត្តលេខ០០០៣១៩ | មេបញ្ជាការរង យោធភូមិភាគទី២ |
| ៣-វរសេនីយ៍ឯក | សុខ | យាន | អត្តលេខ០០០៨៥៧ | ទីប្រឹក្សាអគ្គមេបញ្ជាការ |

មាត្រា២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០០១

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ: ៧៤០ ច.ល

បានជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រី
សហរដ្ឋមន្ត្រីក្រសួងការពារជាតិ
ព្រះហស្ថលេខា និង ហត្ថលេខា
ព្រះអម្ចាស់ ស៊ីសុវត្ថិ សិរីរត្ន ទៀ បាញ់

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ១០ ឆ្នាំ ២០០១

អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៩៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## <u>សំរេច</u>

<u>មាត្រា១</u>: ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ២ លានរៀល ( ពីរលានរៀល ) ពីជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) មកជំពូក ៣២ ( អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ ; បង់វិភាគទានអោយអង្គការអន្តរជាតិនានា ) របស់ក្រសួងពត៌មាន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

<u>មាត្រា២</u>: ឥណទានថវិកា ក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ សំរាប់បង់វិភាគទានប្រចាំឆ្នាំជូនអង្គការ *Asia Pacific Institute for Broadcasting Development A I B D* ។

<u>មាត្រា៣</u>: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចំលងជូន</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ . ឯកសារ

បានយកសេចក្ដីជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
[illegible]

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បណ្ណសារដ្ឋានជាតិ

ថ្ងៃទី_____ខែ_____ឆ្នាំ_______

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីនីតិវិធីនៃការបើកផ្តល់មុន ដោយអាណត្តិបើកប្រាក់

## សំរាប់

- ចំណាយដំណើរការរៀបចំការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ចំណាយមូលនិធិសំរាប់ជួសជុលថែទាំផ្លូវថ្នល់
- ចំណាយសំរាប់កម្មវិធីអភិវឌ្ឍន៍សុខាភិបាលស្រុកប្រតិបត្តិឈានមុខ (ADD) និង ចំណាយសំរាប់កម្មវិធីសកម្មភាពអាទិភាព (PAP)

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបាន កែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៨/០៤ ចុះថ្ងៃទី ២០ ខែ មិនា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតគណនីពិសេសរបស់រតនាគារជាតិ សំរាប់ការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

-បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** -អនុក្រឹត្យនេះមានគោលបំណងកែសម្រួលនីតិវិធីនិងបែបបទបញ្ចេញអាណត្តិបើកប្រាក់សំរាប់ :

- ចំណាយដំណើរការរៀបចំការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ចំណាយមូលនិធិសំរាប់ជួសជុលថែទាំផ្លូវថ្នល់
- ចំណាយសំរាប់កម្មវិធីអភិវឌ្ឍន៍សុខាភិបាលស្រុកប្រតិបត្តិឈានមុខ (ADD)

និងចំណាយ សំរាប់កម្មវិធីសកម្មភាពជាអាទិភាព (PAP) ។

គោលដៅនៃកិច្ចប្រតិបត្តិការនេះ គឺ ដើម្បីធានាសម្រេចបាននូវប្រសិទ្ធភាពចំណាយដល់កិច្ចការទាំងបីខាងលើ សំខាន់ធានានូវភាពទៀងទាត់ និងទាន់ពេលវេលា ។

**មាត្រា២:** -ដោយបដិប្បញ្ញត្តិ ទៅនឹងមាត្រា ៨ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ និងមាត្រា ៩ នៃអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល រាល់ការបើកផ្តល់មុនសំរាប់មុខសញ្ញាចំណាយទាំងឡាយដែលមានចែងនៅក្នុងមាត្រា ៣ ខាងក្រោម ត្រូវធ្វើឡើងដោយអាណត្តិបើកប្រាក់ ដោយគ្រាន់តែភ្ជាប់ជាមួយនូវគំរោងចំណាយលំអិត ។

**មាត្រា៣:** -មុខសញ្ញាចំណាយដែលបើកផ្តល់មុនដោយអាណត្តិបើកប្រាក់មានដូចតទៅ :

- ចំណាយសំរាប់ការរៀបចំបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំកាបោះឆ្នោត
- ចំណាយមូលនិធិសំរាប់ជួសជុលថែទាំផ្លូវថ្នល់
- ចំណាយសំរាប់កម្មវិធីអភិវឌ្ឍន៍សុខាភិបាលស្រុកប្រតិបត្តិឈានមុខ (ADD)

និងចំណោយសំរាប់កម្មវិធីសកម្មភាពជាអាទិភាព (PAP) ។

**មាត្រា៤:** -រាល់ចំណាយជួសជុលថែទាំ ផ្គត់ផ្គង់ទំនិញ-សេវា សំរាប់បំរើការងារដូចមានចែងក្នុងមាត្រា ៣ ខាងលើ ត្រូវអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ ជាធរមាន ។

**មាត្រា៥:** -ក្រសួង ស្ថាប័ន ឬ អង្គភាពដែលគ្រប់គ្រងចំណាយដូចមានចែងក្នុងមាត្រា ៣ ខាងលើ ត្រូវមានភារកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្ទាប់ពីកិច្ចប្រតិបត្តិការចំណាយលើការងារនិមួយៗត្រូវបានបញ្ចប់ ។ ក្នុងករណីមានប្រាក់នៅសល់ត្រូវបង់ចូលថវិកាជាតិវិញ ។ មុខសញ្ញាចំណាយទាំងអស់នេះ ត្រូវស្ថិតក្រោមយន្តការនៃការធ្វើសវនកម្មក្រោយចំណាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ ។

**មាត្រា៦:** -កិច្ចប្រតិបត្តិការចំណាយទាំងអស់នេះ ត្រូវមានការណែនាំអនុវត្តជាក់ស្តែងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា៧:** -រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រឹទ្ធាចារ្យប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រដ្ឋមន្ត្រីក្រសួងសាធារណៈការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០១

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ចម្លងជូន

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ដូចមាត្រា ៧ " ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាល និង សុក្រឹតការវិជ្ជាជីវៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ១៩.អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០១

## សំរេច

**មាត្រា ១ .-**

ត្រូវបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីដោយកំណត់ឈ្មោះថា មជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវី ។

**មាត្រា ២ .-**

មជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវី ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់ក្រុមប្រឹក្សាគណៈមេធាវី និងក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងយុត្តិធម៌ ។

**មាត្រា ៣ .-**

មជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការ វិជ្ជាជីវៈមេធាវី ត្រូវមានបទបញ្ជាផ្ទៃក្នុងមួយ ដែលកំណត់ នូវលក្ខខណ្ឌក្នុងដំណើរការរបស់មជ្ឈមណ្ឌលនេះ ។

**មាត្រា ៤ .-**

ក្រុមប្រឹក្សាគណៈមេធាវី និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ តំណាង ជាអ្នកកំណត់នូវកម្មវិធីសិក្សា និងបែបបទក្នុងការប្រឡងចូល និងការប្រឡងយកវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ។

គណៈមេប្រយោគក្នុងការប្រឡងចូល និងការប្រឡងយកវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវីនេះ ត្រូវមានសមាជិក ចំនួន ៩ រូប ហើយដែលមានសមាសភាព ដូចតទៅ :

| | | |
|---|---|---|
| -ប្រធានគណៈមេធាវី | | ប្រធាន |
| -តំណាងក្រសួងយុត្តិធម៌ | ០១ រូប | អនុប្រធាន |
| -សមាជិកក្រុមប្រឹក្សាគណៈមេធាវី | ០៤ រូប | សមាជិក |
| -ចៅក្រម | ០១ រូប | សមាជិក |
| -សាស្ត្រាចារ្យច្បាប់ តំណាងមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច | ០១ រូប | សមាជិក |
| -តំណាងក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប | សមាជិក |

គណៈមេប្រយោគខាងលើនេះ ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ។

**មាត្រា ៥ .-**

ប្រភពធនធាន និងថវិកានៃមជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវី ត្រូវបានមកពី :

-គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

-ចំណូលក្នុងការសុំចុះឈ្មោះចូលរៀនរបស់សិស្សមេធាវីកម្មសិក្សា

-ចំណូលក្នុងការសុំចុះឈ្មោះបេក្ខជនប្រឡង

-ជំនួយ និងប្រាក់ឧបត្ថម្ភពីសហគមន៍ជាតិ អន្តរជាតិ អង្គការផ្តល់ជំនួយនានា និងអំណោយរាជរដ្ឋាភិបាល ។

**មាត្រា ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ អោយបានសំរេច តាមភារៈកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៧

-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ

-កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** : ៧៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន ឋបនីយជីវមណ្ឌលបឹងទន្លេសាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការការពារបរិស្ថាននិង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៣៣ក្រ.ច ចុះថ្ងៃទី០៩ ខែមិនា ឆ្នាំ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ស្តីពីការបង្កើតនិងគ្រប់គ្រងឋបនីយជីវមណ្ឌលបឹងទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ ៥៧ អនក្រ /បកចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភះ ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០០១ ។

# សំរេច :

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.–**

បង្កើតលេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប ឱ្យស្ថិតនៅក្រោមគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដើម្បីជួយដល់ការសម្របសម្រួល ពង្រឹងការងារទំនាក់ទំនង និង សហការរវាងក្រសួង-ស្ថាប័នជាតិ និងអន្តរជាតិ អាជ្ញាធរដែនដី និងសង្គមស៊ីវិល ក្នុងកិច្ចការការពារ និងគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប ប្រកបដោយនិរន្តរភាព នៅក្នុងតំបន់ភូមិសាស្ត្រ និងដែនសមត្ថកិច្ច ដែលត្រូវបានប្រគល់ឱ្យ ។

**មាត្រា២.–**

លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប មានឋានៈស្មើនាយកដ្ឋាននៃបណ្តាក្រសួង ដែលដឹកនាំដោយលេខាធិការ ១រូប មកពីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងលេខាធិការ-រងមួយចំនួន មកពីក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្នុងនោះ លេខាធិការរងមកពីក្រសួងបរិស្ថាន ទទួលបន្ទុកជាលេខាធិការរងអចិន្ត្រៃយ៍ ។

លេខាធិការដ្ឋានមានមន្ត្រីបំរើការងារមកពី ក្រុមសម្របសម្រួលបច្ចេកទេសបឹងទន្លេសាប ដែលកំពុងបំរើការងារឱ្យថបនីយជីវមណ្ឌលបឹងទន្លេសាប ។ ដោយផ្អែកលើផែនការប្រចាំឆ្នាំ លេខាធិការដ្ឋានអាចលើកសំណើជ្រើសរើសសមាជិកបន្ថែមពី ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលជាសមាជិកនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

**មាត្រា៣.–**

ក្នុងការអនុវត្តការងារសម្របសម្រួល ពង្រឹងការងារទំនាក់ទំនង និងសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ក្នុងកិច្ចការពារ និងគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប ប្រកបដោយនិរន្តរភាព លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប ត្រូវឱ្យមានផ្នែកបច្ចេកទេសមួយចំនួន ដែលជារចនាសម្ព័ន្ធ ជាអាទិ៍គឺៈ ផ្នែកយុទ្ធសាស្ត្រនយោបាយ និងបណ្តាញការងារ ផ្នែកសិក្សាស្រាវជ្រាវតាមដានត្រួតពិនិត្យ និងទិន្នន័យពត៌មាន ។

ផ្នែកនីមួយៗ មានឋានៈស្មើនឹងការិយាល័យ ដែលដឹកនាំដោយប្រធាន និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

**មាត្រា៤._**

លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប ដែលជាសេនាធិការរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានភារកិច្ច :

- រៀបចំយុទ្ធសាស្ត្រ និងយន្តការ ដើម្បីសំរេចគោលបំណងសំខាន់ៗ របស់ថបនីយជីវមណ្ឌលបឹងទន្លេសាប
- បង្កើតប្រពន្ធ័គ្រប់គ្រងទិន្នន័យ ពត៌មានចម្រុះ សំរាប់ថបនីយជីវមណ្ឌលបឹងទន្លេសាប និង យន្តការផ្លាស់ប្តូរទិន្នន័យពត៌មាន ក្នុងចំណោមស្ថាប័នពាក់ព័ន្ធ
- តាមដានពិនិត្យ វាយតំលៃ និងធ្វើរបាយការណ៍ស្តីពីស្ថានភាពថបនីយជីវមណ្ឌលបឹងទន្លេសាប ក្នុងរយៈពេលពី ៤ ទៅ ១០ ឆ្នាំម្តង តាមតំរូវការចាំបាច់
- សម្របសម្រួល និងសហការជាមួយស្ថាប័នអង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យឡើងវិញ នូវច្បាប់ បទប្បញ្ញត្តិនានាដើម្បីធ្វើអនុសាសន៍លើកស្ទួយការគ្រប់គ្រង ថបនីយជីវមណ្ឌលបឹងទន្លេសាប ប្រកបដោយនិរន្តរភាព
- សម្របសម្រួលរៀបចំប្រព័ន្ធសិក្សាស្រាវជ្រាវ និងឃ្លាំមើលជីវចំរុះ
- បង្កើតបណ្តាញទំនាក់ទំនងជាមួយនឹងអាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល ស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ក្នុងគោលបំណងប្រមូលពត៌មាន សំរាប់បំរើដល់ការធ្វើផែនការស្នើសេចក្តីសំរេចចិត្ត និងការអនុវត្តផែនការអភិរក្ស និងគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប
- រៀបចំកិច្ចប្រជុំ ឬវេទិកាពិភាក្សា ដើម្បីពិភាក្សាលើបញ្ហា ដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប និងរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំ
- សម្របសម្រួលជាមួយនឹងក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត ក្នុងគោលបំណងរៀបចំ លើកគម្រោងផែនការ ដើម្បីរកជំនួយពីរាជរដ្ឋាភិបាល និងអន្តរជាតិ
- រៀបចំរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ អំពីសកម្មភាពរបស់លេខាធិការដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាផ្តល់ឱ្យ ។

## ជំពូកទី ២
## អវសានប្បញ្ញត្តិ

**មាត្រា៥.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន និង អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់ខេត្ត-ក្រុង
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ១៥០ លានរៀល ( មួយរយហាសិបលានរៀល ) ពីជំពូក ៤០ (ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយ ដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់ក្រសួងពត៌មាន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

**មាត្រា២:** ឥណទានថវិកា ក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ សំរាប់ចំណាយក្រុមការងារពិសេស ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
រដ្ឋមន្ត្រីស្តីទី

អ៊ុក រ៉ាប៊ុន

ជំនួសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៨០៩...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អ្នកតំណាងរាស្ត្រមណ្ឌលតាកែវ

### សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ០២ រូប ដែលបានបរិច្ចាគ ធនធានផ្ទាល់ខ្លួន ជួយកសាង សាលារៀន ព្រះវិហារ កុដិ ក្លោងទ្វារ របងវត្ត ប្រាង្គ និង សាលាទទួលភ្ញៀវ នៅក្នុងវត្តសមរលាវ ឃុំពោធិរំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមានរាយព្រះនាមនិងនាមខាង ក្រោមនេះ÷

១-ព្រះតេជគុណ **សួស ជុំ** ព្រះចៅអធិការវត្តសមរលាវ បច្ច័យចំនួន ១៨៧.០៨៤.២០០ រៀល

២-លោកគ្រូ **ខួច នែម** ហៅ **ឈុំ** និង គ្រួសារ ទឹកប្រាក់ចំនួន ១៥.០០០ ដុល្លារអាមេរិក

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៤១០...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងធនធានទឹក និង ឧតុនិយម

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសំរឹទ្ធការងារ** ជូនមន្ត្រីរាជការ ១០ រូប នៃមន្ទីរធនធានទឹក និង ឧតុនិយម ខេត្តបាត់ដំបង ដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ក្នុងការចូលរួមសហការកែលំអប្រព័ន្ធស្រោចស្រព អាងកំពីងពួយ ដូចមានរាយនាមខាងក្រោមនេះ ÷

| | | | |
|---|---|---|---|
| ១-លោក | **អៀង** | **អ៊ាម** | អនុប្រធានមន្ទីរ |
| ២-លោក | **ហុង** | **គិមសាន** | អនុប្រធានមន្ទីរ |
| ៣-លោក | **លុយ** | **អ៊ើម** | ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក |
| ៤-លោក | **យឿន** | **យឿន** | ប្រធានការិយាល័យធារាសាស្ត្រកសិកម្ម |
| ៥-លោក | **ឈួម** | **ចិន** | អនុប្រធានការិយាល័យធារាសាស្ត្រកសិកម្ម |
| ៦-លោក | **ឃីន** | **ឃន** | អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក |
| ៧-លោក | **គិម** | **សុផៃ** | អនុប្រធានការិយាល័យគ្រប់គ្រង និងអភិរក្សធនធានទឹក |
| ៨-លោក | **អ៊ុក** | **សារិត** | មន្ត្រីការិយាល័យធារាសាស្ត្រកសិកម្ម |

៩-លោក រិត ឈឿត អនុប្រធានការិយាល័យឧតុនិយម និង ជលសាស្ត្រ

១០-លោក ឈីន សុខុម មន្ត្រីការិយាល័យធារាសាស្ត្រកសិកម្ម

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងធនធានទឹកនិងឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ.ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ_______

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤១១...អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយសហមេត្រី

* * * * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនតំណាងអង្គការចំនួន ០២ រូប ដែលបានផ្ដល់ជំនួយសំរាប់គំរោងអភិវឌ្ឍន៍ពហុវិស័យនៅតំបន់កំពីងពួយ ខេត្តបាត់ដំបង និង គំរោងកសាងសមត្ថភាពនៅក្រសួងធនធានទឹក និង ឧតុនិយម ដូចមានរាយនាមខាងក្រោមនេះ ÷

១-លោក Martin Peter Gillham ប្រធានក្រុមអង្គការ ADB

២-លោក Giovanni Santavicca តំណាងអង្គការ APS

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤១២ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ប្រគេន និង ជូនសប្បុរសជន ០៣ រូប ដែលបានបរិច្ចាគនូវបច្ច័យ និង ថវិកា ដើម្បីចូលរួមចំណែកក្នុងការកសាងសមិទ្ធផលនានាជាច្រើន ក្នុងវិស័យព្រះពុទ្ធសាសនា ស្ថិតនៅក្នុងវត្តអង្គសិរីសួស្តី ភូមិសំរោងត្បូង ស្រុកពញាឮ ខេត្តកណ្តាល ដូចមានរាយព្រះនាម និង នាមខាងក្រោម ÷

១-ព្រះគ្រូ ធូច ចន ( ចិរញ្ញាណោ ) ចៅអធិការវត្តអង្គសិរីសួស្តី ដឹកនាំកសាងអស់បច្ច័យសរុបចំនួន ៣៤៨.៥៩២ USD និង ៦.000.000 ៛

២-លោកជំទាវ ម៉ែន សំអន តំណាងរាស្ត្រមណ្ឌលស្វាយរៀង ថវិកា ១៣.៤៧០ USD និង ២០.000.000 ៛

៣-លោកស្រី ពឹខ ឆះថេខ នៅក្រុងភ្នំពេញ ថវិកា ២០.000 USD និង ២០.000.000 ៛

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។៤

រាជធានីភ្នំពេញ.ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

[illegible] សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- [illegible]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤១៣ អនក្រ-តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

### សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ០៣ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ដើម្បីជួយស្ថាបនាលើវិស័យនានា ធ្វើអោយមានការរីកចំរើនជាបន្តបន្ទាប់ ដូចជា : ជីកប្រឡាយ ទំនប់ និង ដីស្រែដែលដោះស្រាយគោលនយោបាយ ស្ថិតនៅក្នុងឃុំត្របែក ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម ÷

១-លោក ថ្វាង សុជាន់ ប្រធានក្រុមហ៊ុន ថ្វាងសុជាន់ពាណិជ្ជ ថវិកា ៧២.១០៩ USD

២-ឯកឧត្តម ជាម ហ៊ីម អភិបាលរងទី ២ ខេត្តកោះកុង ថវិកា ៤០.០០០ USD

៣-លោក សុក សឺន ប្រធានមន្ទីរអភិវឌ្ឍន៍ ខេត្តព្រៃវែង ថវិកា ៣០.០០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨១៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០១ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមកសាងព្រះវិហារ សាលារៀន ផ្លូវថ្នល់ ស្ពាន និង សមិទ្ធិផលផ្សេងៗក្នុងឃុំភូមិធំ ស្រុកគៀនស្វាយ ខេត្តកណ្តាល ដូចមាននាម ខាងក្រោម ÷

-ឯកឧត្តម **អ៊ុក ស៊ីផាន** ថវិកាចំនួន ៥៤.៦១៤ ដុល្លាអាមេរិក

**មាត្រា២:** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តន៍អនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ជរដ្ឋាភិបាលកម្ពុជា

េខ : ៤១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងផ្ទេរភារកិច្ចមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទ ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៦៩៩ / ០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ / អនក្រ.បក / ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

## សំរេច

មាត្រា ១ : ត្រូវបានតែងតាំង និងផ្ទេរភារកិច្ចមន្ត្រីរាជការ ចំនួន ០៤ រូប នៃក្រសួងធនធានទឹក និងឧតុនិយម ដូចមានរាយនាមខាងក្រោម ÷

១- លោក ព្រហ្ម សារឿន ជាអគ្គាធិការរង នៃក្រសួងធនធានទឹក និងឧតុនិយម

២- លោក មុី លីហួត ជាអគ្គនាយករងកិច្ចការរដ្ឋបាល នៃក្រសួងធនធានទឹក និងឧតុនិយម

៣- លោក ឯម ប៊ុនធឿន ជាប្រធាននាយកដ្ឋានវិស្វកម្ម នៃក្រសួងធនធានទឹក និងឧតុនិយម

៤- លោក ស៊ិន ឫទ្ធី ជាប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធនធានទឹក និងឧតុនិយម

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤១៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ** ជូនអគ្គលេខាធិការរងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទចំនួន ០៣ រូប ដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់ ក្នុងការបំរើប្រទេសជាតិលើការងារស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ដូចមានរាយនាមខាងក្រោមនេះ ÷

១-ឯកឧត្តម **អ៊ូ គឹមសន**

២-ឯកឧត្តម **មួង សារេត**

៣-ឯកឧត្តម **សូត្រ សយ**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧ សសរ

## សេចក្តីសំរេច

## ស្តីពី

## ការបន្ថែមសមាសភាពគណៈកម្មការចំរុះអន្តរក្រសួង ដោះស្រាយបញ្ហារថយន្តចង្កូតស្តាំ

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងសេចក្តីសំរេចលេខ០៣ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដោះស្រាយបញ្ហារថយន្តចង្កូតស្តាំ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និងជាប្រធានគណៈកម្មការចំរុះអន្តរក្រសួង ដោះស្រាយបញ្ហារថយន្តចង្កូតស្តាំ

## សំរេច

**ប្រការ១.**-លោក ពៅ ម៉ាលី អគ្គនាយករងនៃអគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវបានតែងតាំងជាលេខាធិការរងអចិន្ត្រៃយ៍របស់គណៈកម្មការចំរុះអន្តរក្រសួងដោះស្រាយបញ្ហារថយន្តចង្កូតស្តាំ ។

ប្រការ២.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង សាមីខ្លួន ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី៨០ ខែ កញ្ញា ឆ្នាំ២០០១

ឧបនាយករដ្ឋមន្ត្រី

៩៦ ៤៦២

ចំលងជូន

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"។

-ដូចប្រការ១ និងប្រការ២

"ដើម្បីអនុវត្ត"។

-ឯកសារ-កាលប្បវត្តិ ។

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៦ សរ

## សារាចរ

## ស្តីពីការរៀបចំការងារតំកល់ឯកសារជាតិ

ការងារតំកល់ឯកសារជាតិ ត្រូវបានរៀបចំឱ្យមានដំណើរការយូរមកហើយ តែបច្ចុប្បន្ននៅមានការខ្វះខាតខ្លះៗក្នុងការរៀបចំនិងថែរក្សាឯកសារឱ្យបានល្អតាម ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ។ ឯកសារប្រវត្តិសាស្ត្រត្រូវរក្សាទុកនៅប្រទេសជាតិក្រោមរូបភាពផ្សេងៗ ដូចជា ឯកសាររដ្ឋបាល-សៀវភៅ-ប្លង់-ផែនទី រូបថត ខ្សែអាត់ថតសម្លេង ខ្សែអាត់ថតរូបភាព ឧបករណ៍ផ្ទុកពត៌មានប្រើតាមកុំព្យូទ័រ សាស្ត្រាស្លឹករឹត ។ល។ ដែលក្រសួង ស្ថាប័នជាតិនានា និងខេត្ត-ក្រុង ទូទាំងប្រទេសបាននិងកំពុងដំណើរការសកម្មភាពធ្វើជាមធ្យោបាយគ្រប់គ្រងអភិវឌ្ឍន៍ប្រទេស គឺជាទ្រព្យសម្បត្តិរបស់ប្រទេសជាតិគ្រប់ជំនាន់ដ៏មានតំលៃពុំអាចកាត់ថ្លៃបានឡើយ ។ឯកសារជាតិទាំងនេះមានសារៈសំខាន់ណាស់សំរាប់បំរើការស្រាវជ្រាវ រៀនសូត្រដើម្បីស្វែងរកការអភិវឌ្ឍន៍ប្រទេសជាតិ ទៅថ្ងៃអនាគត ។

ហេតុនេះដើម្បីឱ្យការរៀបចំការងារតំកល់ឯកសារជាតិមានដំណើរការល្អក្នុងការគ្រប់គ្រងនិងថែរក្សាឯកសារឱ្យបានឯកភាពគ្នាទូទាំងប្រទេសស្របតាមលក្ខណៈបច្ចេកទេស រាជរដ្ឋាភិបាលធ្វើការណែនាំដល់ឯកឧត្តម លោកជំទាវ ដែលជាប្រធានស្ថាប័នជាតិ ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្តក្រុងទាំងអស់រៀបចំឱ្យមានជារចនាសម្ព័ន្ធការងារគ្រប់គ្រង និងតំកល់ឯកសារជាតិឱ្យបានល្អឡើងវិញ ហើយជំហ៊ានដំបូងត្រូវដំណើរការតាមទិសដៅដូចតទៅ :

## I-ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងការងារតំកល់ឯកសារ :

១-គ្រប់ក្រសួង ស្ថាប័នជាតិត្រូវបង្កើតឱ្យមាន :

- នាយកដ្ឋានតំកល់ឯកសារ ឬ
- ការិយាល័យតំកល់ឯកសារ ឬ
- ផ្នែកតំកល់ឯកសារ សំរាប់ទទួលខុសត្រូវការងារតំកល់ឯកសាររបស់ស្ថាប័ននីមួយៗដោយផ្ទាល់ ។ការបង្កើតនាយកដ្ឋានឬការិយាល័យឬផ្នែកដូចពោលខាងលើ ត្រូវផ្អែកទៅតាមទំហំការងារតូចឬធំ និងបរិមាណឯកសារ តិចឬ ច្រើនតាមការជាក់ស្តែង ។

២-ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបង្កើតការិយាល័យតំកល់ឯកសារមួយ ក្រោមឱវាទនាយកដ្ឋានរដ្ឋបាល ។

៣-ក្រសួងមហាផ្ទៃត្រូវណែនាំឱ្យខេត្ត-ក្រុងរៀបចំរចនាសម្ព័ន្ធការងារតំកល់ឯកសារ ពីខេត្ត ក្រុងទៅ ស្រុក ខណ្ឌ ឃុំ-សង្កាត់ទូទាំងព្រះរាជាណាចក្រកម្ពុជា ។ នៅខេត្ត-ក្រុងត្រូវបង្កើតជាផ្នែក ឬជាការិយាល័យតំកល់ឯកសារស្ថិត ក្រោមខុទ្ទកាល័យសាលាខេត្ត-ក្រុងផ្ទាល់ ។

៤-នៅថ្នាក់ស្រុក-ខណ្ឌត្រូវមានផ្នែកតំកល់ឯកសារដែលស្ថិតក្រោមការិយាល័យរដ្ឋបាលស្រុក - ខណ្ឌ។ នៅថ្នាក់ឃុំ-សង្កាត់ត្រូវឱ្យស្មៀនឃុំ-សង្កាត់ជាអ្នករៀបចំទុកដាក់ថែរក្សាឯកសាររបស់ឃុំ សង្កាត់នីមួយៗ ។

៥-គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ត្រូវរៀបចំបង្កើតបណ្ណសារដ្ឋានសំរាប់ធានា តំកល់ទុកឯកសារចាស់ថ្មីដែលអង្គភាពចំណុះប្រគល់ជូនតាមការកំណត់ ហើយត្រូវចាត់ឱ្យមានមន្ត្រីជំនាញដាច់ដោយឡែកដើម្បីគ្រប់គ្រងថែរក្សាការពារឯកសារទាំងនោះឱ្យបានល្អ ។

## II-នាយកដ្ឋានឬការិយាល័យតំកល់ឯកសារឬផ្នែកតំកល់ឯកសាររបស់ក្រសួង ស្ថាប័នមានតួនាទីភារកិច្ចដូចតទៅ :

១-ណែនាំនិងជួយដល់មន្ត្រីនៅក្នុងក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងអង្គភាពចំណុះទាំងអស់ឱ្យចេះចងក្រងសំណុំលិខិតឯកសារតាមលក្ខណៈបច្ចេកទេស ដើម្បីទទួលសំណុំលិខិតទាំងនោះទៅតំកល់នៅបណ្ណសារដ្ឋានរបស់ ក្រសួង ស្ថាប័នផ្ទាល់ ។

២-ណែនាំការរៀបចំធ្វើស្ថិតិសំណុំឯកសាររបស់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងអង្គភាពចំណុះឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។

៣-ត្រូវពិនិត្យកែសំរួលចងក្រងឡើងវិញនូវសំណុំលិខិតណាដែលចងក្រងពុំទាន់បានត្រឹមត្រូវ និងមិនទាន់កំណត់រយៈពេលថែរក្សាឯកសារ តាមបច្ចេកទេសនៃការចងក្រងសំណុំលិខិត ។

៤-គ្រប់គ្រងថែរក្សាសំណុំលិខិតឯកសាររបស់ក្រសួង ស្ថាប័ន ខេត្ត-ក្រុងឱ្យបានគង់វង្សល្អ ។

៥-ធ្វើបញ្ជីស្ថិតិគ្រប់គ្រងរាល់សំណុំលិខិតឯកសារទាំងអស់ ដែលអង្គភាពចំណុះក្រសួង ស្ថាប័ន ខេត្ត-ក្រុងប្រគល់ឱ្យ ដើម្បីងាយស្រួលប្រើប្រាស់នៅពេលត្រូវការចាំបាច់ផ្សេងៗ ។

៦-បំរើរាល់ការសិក្សាស្រាវជ្រាវរបស់មន្ត្រីរាជការ នៃក្រសួង ស្ថាប័ន ខេត្ត -ក្រុងផ្ទាល់ និងអតិថិជន ។

៧-ត្រូវប្រគល់សំណុំលិខិតឯកសារ ទៅតំកល់នៅបណ្ណសារដ្ឋានជាតិ តាមការកំណត់របស់នាយកដ្ឋានតំកល់ឯកសារជាតិនៃទីស្តីការគណៈរដ្ឋមន្ត្រី លើកលែងតែក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដែលត្រូវគ្រប់គ្រងថែរក្សាការពារសំណុំលិខិតឯកសារនៅបណ្ណសារដ្ឋានរបស់ក្រសួងដោយផ្ទាល់ ។

មន្ត្រីរាជការដែលធ្វើការនៅនាយកដ្ឋាន ឬការិយាល័យ ឬផ្នែកតំកល់ឯកសាររបស់ក្រសួង ស្ថាប័នមានភារកិច្ចទទួលខុសត្រូវបណ្ណសារដ្ឋានក្រសួង ស្ថាប័នដោយផ្ទាល់ ។

## III-ភារកិច្ចរបស់នាយកដ្ឋាន ឬការិយាល័យ ឬផ្នែកតំកល់ឯកសាររបស់ក្រសួង ស្ថាប័ននានាជាមួយនាយកដ្ឋានតំកល់ឯកសារជាតិ :

១-ត្រូវទាក់ទងនិងសហការការងារ ដើម្បីសិក្សាស្រាវជ្រាវដកស្រង់បទពិសោធន៍ការងារ បច្ចេកទេសតំកល់ឯកសារជាតិ ដោយធ្វើកម្មសិក្សាជាក់ស្តែង ឬសិក្សាស្រាវជ្រាវច្បាប់ គោលការណ៍ និងមេរៀន ស្តីពីបច្ចេកទេសការងារតំកល់ឯកសារ ។

២-បញ្ជូនមន្ត្រីរាជការ ទៅបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេសគ្រប់គ្រងឯកសារ ដែលរៀបចំដោយនាយកដ្ឋានតំកល់ឯកសារជាតិ ស្របតាមគោលការណ៍អភិវឌ្ឍន៍របស់ប្រទេសជាតិ ។

៣-ចូលរួមសិក្ខាសាលា និងអង្គប្រជុំនានាតាមការរៀបចំឡើងដោយនាយកដ្ឋានតំកល់ឯកសារជាតិនៃទីស្តីការគណៈរដ្ឋមន្ត្រី ។

៤-ទាក់ទងស្វែងរកព័ត៌មានអំពីគំរូឧបករណ៍សំភារៈ បរិក្ខារបច្ចេកទេសគ្រប់គ្រងថែរក្សាឯកសារជាតិ ដូចជា ទូ ធ្នើ ប្រអប់ដាក់ឯកសារ និងឧបករណ៍អេឡិចត្រូនិចផ្សេងៗជាដើម ។

៥-ផ្តល់របាយការណ៍តាមការកំណត់ដល់នាយកដ្ឋានតំកល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី អំពីការងារតំកល់ឯកសារ ។

## IV-រយៈពេលថែរក្សាឯកសាររបស់ក្រសួង ស្ថាប័ន និងអង្គភាពចំណុះ :

១-មន្ត្រីដែលធ្វើការជំនាញនៅតាមអង្គភាពចំណុះក្រសួង ស្ថាប័ន អាចគ្រប់គ្រងរក្សាទុកនូវសំណុំលិខិតឯកសារដែលបានដោះស្រាយការងារចប់សព្វគ្រប់រួចហើយ បានត្រឹមតែរយៈពេលមួយឆ្នាំប៉ុណ្ណោះ ។បន្ទាប់ពីនេះត្រូវប្រគល់សំណុំលិខិតឯកសារនោះទៅឱ្យបណ្ណសារដ្ឋានក្រសួង ស្ថាប័នតំកល់ទុក ។

២-ក្រសួង ស្ថាប័ន អាចរក្សាទុកសំណុំលិខិតឯកសាររហូតដល់ផុតតម្លៃនៃការប្រើប្រាស់ ទើបត្រូវយកសំណុំលិខិតឯកសារទាំងនោះទៅប្រគល់ជូនបណ្ណសារដ្ឋានជាតិ នៃ នាយកដ្ឋានតំកល់ឯកសារជាតិចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ជាអ្នកគ្រប់គ្រងតំកល់ទុកជាឯកសារជាតិ ។

៣-ចំពោះក្រសួងមហាផ្ទៃត្រូវណែនាំឱ្យខុទ្ទកាល័យសាលាខេត្ត-ក្រុងប្រគល់សំណុំលិខិតឯកសារដែលផុតតម្លៃនៃការប្រើប្រាស់ទៅឱ្យបណ្ណសារដ្ឋានខេត្ត-ក្រុងជាអ្នកគ្រប់គ្រងតំកល់ទុក ។ ចំណែកឯឯកសារ នគរបាលត្រូវបញ្ជូនមកតំកល់នៅបណ្ណសារដ្ឋានក្រសួងមហាផ្ទៃ ។

៤-ចំពោះក្រសួងការពារជាតិ ត្រូវណែនាំរាល់អង្គភាពចំណុះឱ្យប្រគល់ឯកសារដែលផុតតំលៃនៃការប្រើប្រាស់ទៅឱ្យបណ្ណសារដ្ឋានក្រសួងការពារជាតិតំកល់ថែរក្សាទុក ។

៥-ចំពោះក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវណែនាំគ្រប់ស្ថានឯកអគ្គរាជទូតនិងកុងស៊ុលកម្ពុជាប្រចាំការនៅបរទេសឱ្យប្រគល់ឯកសារដែលផុតតម្លៃនៃការប្រើប្រាស់ ទៅតំកល់នៅបណ្ណសារដ្ឋានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

៦-ចំពោះលិខិតប្រគល់-ទទួលឯកសារត្រូវធ្វើជាពីរច្បាប់: អង្គភាពប្រគល់ត្រូវរក្សាទុកមួយច្បាប់ ហើយអង្គភាពទទួលត្រូវរក្សាទុកមួយច្បាប់ ។

៧-ចំពោះករណីអង្គភាពពីរដែលត្រូវបានបញ្ចូលគ្នាជាអង្គភាពតែមួយគឺ អង្គភាពបង្កើតថ្មីជាអ្នកគ្រប់គ្រង ថែរក្សាឯកសារទុកទាំងអស់ ។

៨-ចំពោះអង្គភាពមួយ ដែលត្រូវបំបែកចេញបង្កើតជាអង្គភាពពីរ ឬច្រើនអង្គភាព ឯកសារណាពាក់ព័ន្ធនិងអង្គភាពជំនាញណា អង្គភាពជំនាញនោះជាអ្នកគ្រប់គ្រងថែរក្សាទុក ។

៩-ចំពោះអង្គភាពគណៈកម្មាធិការណាមួយដែលបានបង្កើតរួចហើយត្រូវរំសាយ រាល់សំណុំលិខិតឯកសារទាំងអស់ត្រូវតែប្រគល់ទៅឱ្យបណ្ណសារដ្ឋានរបស់ក្រសួង ស្ថាប័ន និងខេត្ត-ក្រុងជាអ្នកគ្រប់គ្រងរក្សាទុក ។

១០-ចំពោះក្រសួងស្ថាប័នណាមួយ ដែលត្រូវរំសាយ រាល់សំណុំលិខិតឯកសារទាំងអស់ត្រូវប្រគល់ទៅអោយបណ្ណសារដ្ឋានជាតិនៃនាយកដ្ឋានតំកល់ឯកសារជាតិនៃទីស្តីការគណៈរដ្ឋមន្ត្រី ។

## V- ការប្រគល់ឯកសារទៅតំកល់ :

១-គ្រប់ក្រសួង ស្ថាប័នជាតិទាំងអស់រួមទាំងក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិត្រូវប្រគល់ឯកសាររបបចាស់មុនឆ្នាំ ១៩៧៩ទៅបណ្ណសារដ្ឋានជាតិដើម្បីតំកល់ទុកជាប្រវត្តិសាស្ត្រនៅចុងឆ្នាំ២០០១ ។

២-គ្រប់ក្រសួង ស្ថាប័នទាំងអស់ ត្រូវប្រគល់នូវឯកសារពីឆ្នាំ១៩៧៩ ដែលផុតតម្លៃនៃការប្រើប្រាស់ ទៅបណ្ណសារដ្ឋានជាតិដើម្បីតំកល់ទុកជាប្រវត្តិសាស្ត្រ ។

៣-គ្រប់មន្ទីរខេត្ត-ក្រុងទាំងអស់ត្រូវប្រគល់ឯកសារទៅតំកល់នៅ បណ្ណសារដ្ឋានខេត្ត-ក្រុងតាមការកំណត់ដូចមានចែងក្នុងចំណុចទី២ដែរ ។

៤-មុនពេលប្រគល់ឯកសារទៅតំកល់នៅបណ្ណសារដ្ឋានជាតិ គ្រប់ក្រសួង ស្ថាប័នទាំងអស់ត្រូវធ្វើបញ្ជីស្ថិតិឯកសារដែលត្រូវប្រគល់ភ្ជាប់មកជាមួយ ។

៥-ពេលប្រគល់ឯកសារត្រូវធ្វើលិខិតប្រគល់-ទទួលចំនួនពីរច្បាប់ ភ្ជាប់ជាមួយស្ថិតិឯកសារដែលត្រូវប្រគល់ ។

៦-គ្រប់ក្រសួង ស្ថាប័នណាដែលបានបោះពុម្ពផ្សាយព្រឹត្តិប័ត្រ ឬទស្សនាវដ្តីត្រូវប្រគល់ទៅតំកល់នៅបណ្ណសារដ្ឋានជាតិរៀងរាល់លេខចំនួន៣ច្បាប់ ។

## VI-ការបំផ្លាញឯកសារ :

គ្រប់ក្រសួង ស្ថាប័នជាតិ និង មន្ទីរខេត្ត-ក្រុងទាំងអស់ គ្មានសិទ្ធបំផ្លាញឯកសារផ្លូវការ ណាមួយឡើយ ។

នៅពេលទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងខេត្ត-ក្រុង ត្រូវអនុវត្តសារាចរនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួលៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខេត្ត-ក្រុង
- នាយកដ្ឋានតំកល់ឯកសារជាតិ
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation - Religion - King

រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia
លេខ ២៧៨២/០១ ក អ ក ក ជ.នា

13 9 ២០០១
14 45 333

# ប្រកាស
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

*****

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ/បក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមសំណើរបស់អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមតំរូវការចាំបាច់នៃការងារ

## សំរេច

**ប្រការ ១**: តែងតាំងលោកស្រី **ឆាន សិដ្ឋា** ជាអនុប្រធាននាយកដ្ឋានគ្រប់គ្រងរដ្ឋបាល គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

វិមានរដ្ឋាភិបាល វិថីស៊ីសុវត្ថិ វត្តភ្នំ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា Government Palace, Sisowath Quay, Wat Phnom, Phnom Penh, Cambo
Tel: (855) 23 981 183, (107), Fax: (855) 23 360 (

**ប្រការ ២**: អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការ នៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍ អគ្គលេខាធិការ នៃគណៈកម្មាធិការវិនិយោគ នាយខុទ្ទកាល័យទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទា និង អភិវឌ្ឍន៍ និងគ្រប់ផ្នែកចំណុះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០១

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**គាត ឈន់**

<u>កន្លែងទទួល:</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អនុប្រធាន ក. អ. ក
- ដូចប្រការ២ "ដើម្បីអនុវត្ត "
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

ភ្នំពេញ, ថ្ងៃទី 10 ខែ កញ្ញា ឆ្នាំ 2001

លេខ 128 ប្រ.ក ក.អ.ជ

ក្រសួងប្រព័ន្ធ... មកដល់ ថ្ងៃទី 11 ខែ 9 ឆ្នាំ 2001 ... 305

# ប្រកាស

## ស្តីពី

## ការចាត់តាំងក្រុមការងារ និងក្រុមដឹកនាំ

## សំរាប់គំរោងការអភិវឌ្ឍន៍កសិកម្ម ក្រោមធនាគារអភិវឌ្ឍន៍អាស៊ី លេខ 1445-CAM (SF)

---

## រដ្ឋមន្ត្រី

## ក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស / រកម ១០៩៦ / ១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញកិច្ចព្រមព្រៀងខ្ចីបុលរវាងរាជរដ្ឋាភិបាលកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 1445 - CAM (SF) ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ១៩៩៦
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ១ ;** ចាត់តាំង លោក **ជី ផន** ភេទប្រុស បរិញ្ញាប័ត្រកសិកម្ម បច្ចុប្បន្នជាមន្ត្រីខុទ្ទកាល័យ អោយជំនួស លោក **សោច ទីយោ** ដែលបានទទួលមរណៈ ដោយប្រគល់អោយទទួលមុខងារជា

មន្ត្រីរដ្ឋបាលក្នុងក្រុមជំនាញគោលនយោបាយ ស្តារថែទាំផ្លូវលំជនបទ នៃគំរោងអភិវឌ្ឍន៍វិស័យកសិកម្ម ក្រោមឥណទានអភិវឌ្ឍន៍អាស៊ីគំរោងលេខ **1445-CAM(SF)** ។

**ប្រការ២** : ខុទ្ទកាល័យ , អគ្គនាយកដ្ឋានទាំងពីរ , អគ្គាធិការដ្ឋាន , គ្រប់នាយកដ្ឋាន គ្រប់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត-ក្រុង និងសាម៉ីជនត្រូវអនុវត្តន៏តាមសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងអភិវឌ្ឍន៍ជនបទ**

**លី-ធុជ**

*ចំលងជូន*
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា
និង អធិការកិច្ច
Ministry of National Assembly-Senate Relations and Inspection

លេខ : 005/01 ទ.រ.ព.អ ០៩០/.

រាជធានីភ្នំពេញ, ថ្ងៃទី 20 ខែ ឧសភា ឆ្នាំ 2001

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិមន្ត្រីរាជការ ដែលត្រូវជូនគ្រឿងឥស្សរិយយស

## រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩/០៥ ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

-បានឃើញអនុក្រឹត្យលេខ ៦៧អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ-បក ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី១៦ ខែ មករា ឆ្នាំ ២០០១ របស់រាជរដ្ឋាភិបាលកម្ពុជា

-តាមសំណូមពរចាំបាច់ ក្នុងការលើកទឹកចិត្ត ដើម្បីជូនគ្រឿងឥស្សរិយយសមន្ត្រីរាជការ របស់ក្រសួងមានភាពសុក្រឹត្យល្អ ។

# សំរេច

**ប្រការ ១ .-** បង្កើតគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិមន្ត្រីរាជការ ត្រូវផ្តល់ជូនគ្រឿងឥស្សរិយយស ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ឃុន ហាំង** | រដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម **ខាយ ឃុនហេង** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម **ហុង ថែម** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤-ឯកឧត្តម **សុខ តុន** | អគ្គនាយករដ្ឋបាលកិច្ចការទូទៅ | សមាជិក |
| ៥-ឯកឧត្តម **ខឹម ជាសោភ័ណ** | អគ្គនាយកអធិការកិច្ច | សមាជិក |
| ៦-ឯកឧត្តម **គ្រួច ប៊ុនលី** | អគ្គនាយកទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា | សមាជិក |
| ៧-លោក **ស៊ឹម សុវណ្ណរិទ្ធិ** | នាយកខុទ្ទកាល័យ | សមាជិក |
| ៨-លោក **ហួត ហាក់** | ប្រធាននាយកដ្ឋានរដ្ឋបាល-បុគ្គលិក | សមាជិក |

**ប្រការ ២ .-** គណៈកម្មការនេះ មានភារកិច្ច :

-រៀបចំលក្ខខ័ណ្ឌ សំរាប់ទទួលគ្រឿងឥស្សរិយយសចំពោះមន្ត្រីរាជការ

-ពិនិត្យលក្ខណៈសម្បត្តិលើចំនួនមន្ត្រីរាជការ ដែលសកម្មការងារ និងគោរពពេលវេលាបានទៀងទាត់ ។

-ពិនិត្យ និងធ្វើសំណើដាក់ជូនរដ្ឋមន្ត្រី លើប្រភេទគ្រឿងឥស្សរិយយស តាមទំហំស្នាដៃដែលបានបំពេញការងារ ។

-ធ្វើសំណើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការរៀងរាល់ពីរឆ្នាំម្តង ។

**ប្រការ ៣ .-** អគ្គនាយកដ្ឋាន ខុទ្ទកាល័យ ព្រមទាំងឯកឧត្តម អស់លោកដែលមានសមាសភាពដូចក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ ៚

រដ្ឋមន្ត្រី

ឃុន ហាំង

**<u>កន្លែងទទួល</u> :**

-គណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

-សាមីខ្លួន

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MOSALVY

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ ៦៣៤ ស.ក.ប.យ.

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០០១

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការកសាងលក្ខន្តិកៈដោយឡែករបស់ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

### រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០២ / នស/ រកម/ ០៦៩៩ / ០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញការចាំបាច់របស់ក្រសួង

### សំរេច

**ប្រការ១.** – បង្កើតគណៈកម្មការមួយដើម្បីកសាងលក្ខន្តិកៈដោយឡែករបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។ សមាសភាពគណៈកម្មការនេះមានដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ឌុច សុវណ្ណារី | អគ្គនាយកកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ | ជាប្រធាន |
| ២- លោក | ទៀវ សុគន្ធ | អគ្គនាយករងកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៣- លោក | ហាំង ស៊ីថា | អគ្គនាយករងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាអនុប្រធាន |
| ៤- លោក | គង់ ឆាន | អគ្គនាយករងសង្គមកិច្ច និងយុវនីតិសម្បទា | ជាអនុប្រធាន |
| ៥- លោក | អៀម យាង | អនុប្រធានក្តាប់រូមនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | ជាសមាជិកអចិន្ត្រៃយ៍ |
| ៦- លោក | ហៀង វ៉ាសនា | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងជំនួយ | ជាសមាជិក |
| ៧- លោក | តូច ចាន់នី | អនុប្រធាននាយកដ្ឋានផែនការស្ថិតិ និង សរុប | ជាសមាជិក |
| ៨- លោក | ដួង ហុង | អនុប្រធានក្តាប់រូមនាយកដ្ឋានហិរញ្ញវត្ថុ និង ផ្គត់ផ្គង់ | ជាសមាជិក |
| ៩- លោក | ហួត ចាន់ធី | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ | ជាសមាជិក |

| | | | |
|---|---|---|---|
| ១០- លោក | ហ៊ូ វុឌ្ឍី | អនុប្រធាននាយកដ្ឋានមុខរបរ និង ហត្ថពលកម្ម | ជាសមាជិក |
| ១១- លោក | អ៊ុក សមវិទ្យា | អនុប្រធាននាយកដ្ឋានសន្តិសុខសង្គម | ជាសមាជិក |
| ១២- លោក | ហ៊ុយ ហានសុង | ប្រធាននាយកដ្ឋាន ពេទ្យការងារ | ជាសមាជិក |
| ១៣- លោក | ហឿង សុផុន | អនុប្រធាននាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈនិងទីផ្សារការងារ | ជាសមាជិក |
| ១៤- លោក | ម៉ែន សុចិត្រ | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិក |
| ១៥- លោក | ជុំ សៀកងួន | អនុប្រធាននាយកដ្ឋានសុខុមាលភាពសង្គម | ជាសមាជិក |
| ១៦- លោក | ម៉ៅ សុវត្ថិ | អនុប្រធាននាយកដ្ឋាន សុខុមាលភាពកុមារ | ជាសមាជិក |
| ១៧- លោក | កែវ សឿន | ប្រធាននាយកដ្ឋាន ស្តារលទ្ធភាពពលកម្ម | ជាសមាជិក |
| ១៨- លោក | ប្លង ណាល់ | ប្រធាននាយកដ្ឋានគ្រប់គ្រងយុវនីតិសម្បទា | ជាសមាជិក |
| ១៩- លោក | កែវ សំណោង | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍យុវនីតិសម្បទា | ជាសមាជិក |
| ២០- លោក | ស៊ឹង ម៉ុន | អនុប្រធាននាយកដ្ឋាន នៃ អគ្គាធិការដ្ឋាន | ជាសមាជិក |

**ប្រការ២.** – គណៈកម្មការនេះមានភារកិច្ច សិក្សាស្រាវជ្រាវ ស្វែងយល់ខ្លឹមសារ ដើម្បីកសាងលក្ខន្តិកៈដោយឡែក របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះ បណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

**ប្រការ៣.** – ឯកឧត្តម និង អស់លោកដូចមានរាយនាមក្នុងប្រការ១មានភារកិច្ចរៀង១ខ្លួនអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

"ដើម្បីជូនជ្រាប"

- ដូចប្រការ៣

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ ៦៣១ ស.ក.ប.យ.

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០០១

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារពិនិត្យ និង ការពារ សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០២ / នស/ រកម/ ០៦៩៩ / ០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ១.** -បង្កើតក្រុមការងារមួយ ដើម្បីទទួលខុសត្រូវ ពិនិត្យ និង ការពារសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។ សមាសភាពក្រុមការងារនេះមានដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម អ៊ិត សំហេង | រដ្ឋមន្ត្រី | ជាប្រធាន |
| ២- ឯកឧត្តម នឹម ធូត | រដ្ឋលេខាធិការ | ជាអនុប្រធាន |
| ៣- លោកជំទាវ ប្រាក់ ចន្ថា | រដ្ឋលេខាធិការ | ជាអនុប្រធាន |
| ៤- ឯកឧត្តម សយ ស៊ីផុន | អនុរដ្ឋលេខាធិការ | ជាសមាជិក |
| ៥- ឯកឧត្តម អ៊ុំ មាន | អគ្គនាយក នៃអគ្គនាយកដ្ឋានការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិក |
| ៦- ឯកឧត្តម ថាច់ សែម | ទីប្រឹក្សាអមក្រសួង | ជាសមាជិក |
| ៧- ឯកឧត្តម រស់ រឿន | ទីប្រឹក្សាអមក្រសួង | ជាសមាជិក |
| ៨- ឯកឧត្តម ណុប លាន | ទីប្រឹក្សាអមក្រសួង | ជាសមាជិក |

| | | |
|---|---|---|
| ៩- លោក កែវ សុខសិទ្ធិ | ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី | ជាសមាជិក |
| ១០-លោក ហួន ជីម៉ុងតៀ | ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី | ជាសមាជិក |
| ១១-លោក អ៊ុក សមវិទ្យា | អនុប្រធាននាយកដ្ឋាន សន្តិសុខសង្គម | ជាសមាជិក |
| ១២-លោក សុខ បូរី | អនុប្រធាននាយកដ្ឋាន សន្តិសុខសង្គម | ជាសមាជិក |

**ប្រការ២.** – ក្រុមការងារនេះមានភារកិច្ច សិក្សាស្រាវជ្រាវ និងស្វែងយល់ខ្លឹមសារ នៃសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម សំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ ដើម្បីផ្តល់យោបល់ ការពារ និង ឆ្លើយនូវសំណួររបស់ស្ថាប័ននីតិប្បញ្ញត្តិ ។

**ប្រការ៣.** – ឯកឧត្តម លោកជំទាវ និង អស់លោកដូចមានរាយនាមក្នុងប្រការ១មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៦ កក្ក

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូនៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ០១.៨៧១/០១ គ.ជ.ប

ទីស្តីការគណៈរដ្ឋមន្ត្រី
បានទទួលថ្ងៃទី ២៦ ៩ ២០០១
ចុះលេខ ១៤៤៥ លេខ ២៤៧

# សេចក្តីសំរេច

ស្តីពី

**ការតែងតាំង អនុគណៈកម្មាធិការអចិន្ត្រៃយ៍**

**ផ្នែកសន្តិសុខ នៃ គជប**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម ១២៩៧.០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស.រកម ០៣០១.០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ ជ.ស_រកត_០១៩៨_០៤២ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ និងសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សប្រក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០១ ស្តីពីកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៣២៥ សជណ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០១ អំពីវិញ្ញត្តិស្តីពីព្រះរាជក្រមដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញបទបញ្ជាផ្ទៃក្នុងរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសំរេចលេខ ០៩_៨៣៥.០១ គជប ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០១
- យោងការចាំបាច់របស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**<u>សំរេច</u>**

**<u>ប្រការ</u>** ១ : តែងតាំងសមាសភាពអនុគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកសន្តិសុខ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១_ឯកឧត្តម **ឆិញ ច័ន្ទវិបុល** | សមាជិក គជប | ជាប្រធាន |
| ២_ឯកឧត្តម **ជូ គុងខួន** | សមាជិក គជប | ជាអនុប្រធាន |
| ៣_ឯកឧត្តម **គួយ ប៊ុនរឿន** | សមាជិក គជប | ជាលេខាធិការ |

**ប្រការ** ២ : អនុគណៈកម្មាធិការអចិន្ត្រៃយ៍ នៃ គជប សាមីខ្លួន អគ្គលេខាធិការ និងនាយកដ្ឋានពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះ តាមមុខការរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព

**ប្រការ** ៣ : សេចក្ដីសំរេចតែងតាំងនេះ មានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខា រហូតដល់មានការសំរេចជាថ្មី

**ប្រការ** ៤ : រាល់សេចក្ដីសំរេចទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្ដីសំរេចនេះ ត្រូវទុកជាមោឃៈ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ_______

ភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០១
ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

ព្រឹទ្ធាចារ្យ ឆេង - ផុន

**កន្លែងទទួល** :

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ការិយាល័យសន្តិសុខថ្នាក់កណ្ដាល
- អនុគណៈកម្មាធិការអចិន្ត្រៃយ៍នៃ គជប
- ដូចប្រការ ២
- គខ/កប គ្រប់ខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ